# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអភិបូជានៅកំពង់សោម
# ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨
*សូមធ្វើជាមនុស្សដ៏វិសុទ្ធ*

អត្ថបទទី១៖ លវ ១៣,១-២.៤៥-៤៦
អត្ថបទទី២៖ ១ករ ១០,៣១-១១,១
ដំណឹងល្អ៖ មក ១,៤០-៤៥

បងប្អូនជាទីស្រឡាញ់!

ព្រះសហគមន៍ឲ្យយើងមើលអ្នកជំងឺឃ្លង ជាមនុស្សដែលគេមិនចង់ប៉ះពាល់ទេ នៅក្នុងអត្ថបទទីមួយ លោកម៉ូសេបានណែនាំឲ្យលោកអរ៉ុនយល់អំពីធម្មវិន័យ ដើម្បីការពារកុំឲ្យប្រជាជនបរិសុទ្ធឆ្លងជំងឺមិនបរិសុទ្ធ។ អ្នកជំងឺនោះគ្មានសិទ្ធិចូលនៅក្នុងភូមិ ឥតមានសិទ្ធិចូលនៅក្នុងព្រះវិហារ ពេលដើរទៅណាគាត់ត្រូវស្រែកខ្លាំងៗថា "**ខ្ញុំជាមនុស្សមិនបរិសុទ្ធ**" ដើម្បីឲ្យអ្នកផ្សេងៗគេដឹងគេនៅឆ្ងាយពីគាត់។ ក្នុងអត្ថបទ "**ក្នុងពេលដែលគាត់កើតជំងឺឃ្លងនោះ គាត់ជាមនុស្សមិនបរិសុទ្ធដូច្នេះគាត់ត្រូវរស់នៅដាច់ឡែកពីគេ**"។

ជាមួយព្រះយេស៊ូថ្ងៃនេះ អ្នកជំងឺឃ្លងមិនខ្លាចទៅជិតព្រះយេស៊ូ ហើយលុតជង្គង់ទូលអង្វរព្រះអង្គថា "**សូមលោកប្រោសខ្ញុំប្របាទឲ្យបានជាស្អាតបរិសុទ្ធ**" មានន័យថាគាត់គោរពព្រះយេស៊ូជាព្រះជាម្ចាស់។ គាត់មិនកំពុងសុំ ឲ្យគ្រូពេទ្យម្នាក់ព្យាបាលគាត់ឲ្យបានជាសះស្បើយ ប៉ុន្តែគាត់បានទៅជួបព្រះយេស៊ូដែលជាតំណាងរបស់ព្រះជាម្ចាស់។ គាត់ដឹងថាព្រះយេស៊ូមិនមែនជាមនុស្សធម្មតាទេ ព្រះយេស៊ូបានដើរពីភូមិមួយទៅភូមិមួយដើម្បីព្យាបាលអ្នកជំងឺ បណ្តេញខ្មោចចេញពីមនុស្ស។ ហេតុនេះហើយ ពេលគាត់នៅជិតព្រះយេស៊ូគាត់លុតជង្គង់ ក្រាបថ្វាយបង្គំដោយទទួលស្គាល់ថាគាត់កំពុងជួបជាមួយព្រះជាម្ចាស់ ដែលអាចណែនាំឲ្យគាត់បានស្អាតបរិសុទ្ធ។ ព្រះយេស៊ូ មានព្រះហឫទ័យអាណិតអាសូរ ព្រះអង្គបានលូកព្រះហស្តទៅពាល់គាត់ ព្រះយេស៊ូមិនខ្លាចអ្វីសោះវាខុសពីអ្វីដែលអ្នកជំងឺនោះទន្ទឹងរង់ចាំពីមនុស្សម្នាក់។ ប៉ុន្តែវាផ្ទុយពីធម្មតា នៅពេលព្រះយេស៊ូប៉ះអ្នកជំងឺឃ្លង ជាអ្នកជំងឺឃ្លងដែលបានឆ្លងភាពដ៏វិសុទ្ធពីព្រះយេស៊ូ ណែនាំឲ្យគាត់ជាសះស្បើយ។ មនុស្សទាំងអស់គេមិនយល់ តែអ្នកជំងឺឃ្លងគាត់យល់ច្បាស់ថាគាត់បានជួបជាមួយព្រះជាម្ចាស់។ នៅពេលគាត់លុតជង្គង់ គាត់បង្ហាញថាគាត់មានជំនឿលើព្រះជាម្ចាស់ ជំនឿដែលគាត់មានលើព្រះយេស៊ូណែនាំឲ្យគាត់ឆ្លងភាពដ៏វិសុទ្ធពីព្រះអង្គ ឲ្យគាត់ទៅជាមនុស្សថ្មី។

ព្រះអង្គបានណែនាំឲ្យគាត់ទៅបង្ហាញខ្លួនក្នុងព្រះវិហារ ដើម្បីឲ្យបូជាចារ្យដែលចេញពីក្រុមអរ៉ុនពីសម័យដើម អាចមើលឃើញមនុស្សមិនបរិសុទ្ធក្លាយជាមនុស្សបរិសុទ្ធ ដោយសារឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

ការអស្ចារ្យនេះ ណែនាំឲ្យយើងគិតអំពីជីវិតរបស់យើងដែរ ជួនកាលយើងជាមនុស្សដែលមិនបរិសុទ្ធ ជួនកាលយើងភ្ជាប់ជាមួយអំពើបាបដែរ ដោយសារយើងមិនទាន់ជាសន្តសន្តិ មិនទាន់ជាមនុស្សដ៏វិសុទ្ធដល់កំពូល។ ដូច្នេះយើងធ្វើដូចម្តេច ដើម្បីអង្គុយនៅក្បែរព្រះយេស៊ូ ដើម្បីបានឆ្លងភាពដ៏វិសុទ្ធរបស់ព្រះអង្គ ណែនាំឲ្យយើងទៅជាមនុស្សបរិសុទ្ធ។ បន្តិចទៀតយើងចូលនៅក្នុងរដូវ៤០ថ្ងៃ ដើម្បីកែប្រែចិត្តគំនិត ឲ្យយើងទៅជាមនុស្សដ៏វិសុទ្ធបន្តិចម្តងៗ គឺទុកឲ្យព្រះយេស៊ូមានទំនាក់ទំនងជាមួយយើង។ ដូច្នេះយើងត្រូវតែលុតជង្គង់អធិដ្ឋាន ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីយកព្រះយេស៊ូជាគំរូ។ អត្ថបទទីពីរ “**សូមយកតម្រាប់តាមខ្ញុំ ដូចខ្លួនខ្ញុំផ្ទាល់បានយកតម្រាប់តាមព្រះគ្រីស្តដែរ**” ឲ្យយើងទីជាមនុស្សបរិសុទ្ធ ដើម្បីឲ្យយើងទៅជាមនុស្សថ្មី ដែលព្រះយេស៊ូណែនាំឲ្យគ្រប់ជំងឺ អំពើបាប ភាពងងឹត... ដែលយើងមាននៅក្នុងខ្លួនយើងអាចលាងអស់ហើយ។ ថ្ងៃនេះសន្តប៉ូ បានណែនាំឲ្យយើងយកព្រះយេស៊ូជាគំរូ ដើម្បីរស់នៅក្នុងជីវិតបច្ចុប្បន្ននេះ។ លោកប៉ូលថា “**ខ្ញុំខំប្រឹងផ្គាប់ចិត្តមនុស្សទាំងអស់ក្នុងគ្រប់កិច្ចការ ដោយមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន គឺស្វែងរកផលប្រយោជន៍សម្រាប់មនុស្សទាំងអស់ ដើម្បីឲ្យគេទទួលការសង្គ្រោះ**” ឲ្យយើងធ្វើដូចម្តេចដើម្បីរស់នៅសម្រាប់បងប្អូនឯទៀតៗ ដើម្បីបើកចិត្តគំនិតឲ្យបងប្អូនឯទៀតៗមានសេចក្តីសុខដែរ។

ពេលយើងនិយាយអំពី ការណែនាំមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន គឺដូចសាលាដុនបូស្កូដែលបានទទួលកូនក្មេង ដែលឪពុកម្តាយទៅឆ្ងាយណែនាំឲ្យគេមានភាពកក់ក្តៅអស់ហើយ។ ព្រះយេស៊ូមានព្រះបន្ទូលថា “**សូមឲ្យកូនក្មេងចូលមករកខ្ញុំចុះ ហើយសូមកែប្រែចិត្តគំនិតឲ្យបានដូចកូនក្មេងនេះ**” ឲ្យយើងធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាឪពុកម្តាយជាពិសេសកូនក្មេង ដែលគ្មានឱកាសទទួលសេចក្តីស្រឡាញ់ពីឪពុកម្តាយ។ លះបង់ប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថាទទួលជីវិតនៅលើផែនដីនេះ សន្តប៉ូលនិយាយថា “**ទោះបីបងប្អូនពិសារម្ហូបអ្វី ពិសារភេសជ្ជៈអ្វី ទោះបីបងប្អូនធ្វើការអ្វីក៏ដោយ ត្រូវធ្វើទាំងអស់ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់**”។ ប្រសិនបើយើងចង់ឆ្លងភាពដ៏វិសុទ្ធពីព្រះយេស៊ូ ពេលយើងធ្វើអ្វីៗក៏ដោយឲ្យយើងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

មនុស្សឃ្លង់នេះ ពេលគាត់លុតជង្គង់ទូលអង្វរព្រះយេស៊ូ ពេលគាត់ឈរឡើងគាត់បានជាស្អាតបរិសុទ្ធ គាត់បានរត់ទៅលើកតម្កើងព្រះជាម្ចាស់ ដើម្បីឲ្យទាំងអស់គ្នាចូលនៅក្នុងអំណរសប្បាយរបស់គាត់ និងជាពិសេសទទួលស្គាល់អំពីឫទ្ធានុភាពរបស់ព្រះយេស៊ូដែលណែនាំឲ្យគាត់ជាសះស្បើយ។

ថ្ងៃនេះជាទិវានៃអ្នកជំងឺ ជាថ្ងៃដែលយើងគោរពព្រះនាងម៉ារីនៅទីក្រុងលូត តាមរយៈទឹកដ៏វិសុទ្ធដែលចេញពីភ្នំ បានណែនាំឲ្យអ្នកជំងឺជាច្រើនបានជាសះស្បើយរយៈ១៥០ឆ្នាំកន្លងមកហើយ។ រាល់ឆ្នាំមានរាប់លាននាក់ ដែលបានទៅដល់ទីនោះដើម្បីចូលទៅក្នុងអាងទឹកដោយសង្ឃឹមថាបានទទួលជីវិតថ្មី និងណែនាំឲ្យយើងទីជាមនុស្សបរិសុទ្ធ។ ព្រះនាងម៉ារីជាសាវ័កមុនគេបង្អស់ ព្រះនាងម៉ារីជាស្ត្រីបរិសុទ្ធមុនគេបង្អស់ ប៉ុន្តែព្រះនាងម៉ារីជាស្ត្រីម្នាក់ធម្មតា ព្រះនាងបានចាប់ដៃយើង ដើម្បីឲ្យយើងចូលនៅក្នុងភាពដ៏វិសុទ្ធរបស់ព្រះយេស៊ូ។ សូមព្រះនាងម៉ារីជួយយើង ឲ្យយើងចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូយ៉ាងជ្រៅដើម្បីទៅជាមនុស្សថ្មី ដើម្បីឆ្លងភាពដ៏វិសុទ្ធពីព្រះយេស៊ូ និងណែនាំឲ្យយើងទាំងអស់ទៅជាមនុស្សដ៏វិសុទ្ធ។ អាម៉ែន៕